ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ : ០៦៧ ក.យ.ប្រក/២៤

# ប្រកាស

# ស្តីពី

# ការផ្តល់អាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្ន ក្នុងសំណុំរឿងក្ស័យធន

២០២៤

មាតិកា

# មាតិកា

## ប្រកាសលេខ ០៦៧ កយ.ប្រក/២៤ ស្តីពី ការផ្តល់អាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន



| |
|---|
| **ជំពូកទី១**<br>**បទប្បញ្ញត្តិទូទៅ**<br>**(ប្រការ១ដល់ប្រការ២)** |
| ប្រការ១.-គោលបំណង និងគោលដៅ |
| ប្រការ២.-វិសាលភាព |
| **ជំពូកទី២**<br>**ស្ថាប័នមានសមត្ថកិច្ច**<br>**(ប្រការ៣ដល់ប្រការ៤)** |
| ប្រការ៣.- ការផ្តល់អាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| ប្រការ៤.- បញ្ជីថ្នាក់ជាតិនៃអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| **ជំពូកទី៣**<br>**លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការផ្តល់ អាជ្ញាបណ្ណជាអភិបាល បណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន**<br>**(ប្រការ៥ដល់ប្រការ១០)** |
| ប្រការ៥ - លក្ខខណ្ឌស្នើសុំអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| ប្រការ៦ - បែបបទ និងនីតិវិធីសម្រាប់ស្នើសុំអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| ប្រការ៧.-ការតម្រូវបន្ថែមសម្រាប់ការផ្តល់អាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| ប្រការ៨.- រយៈពេលសុពលភាពនៃអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| ប្រការ៩.-ការស្នើសុំបន្តអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| ប្រការ១០.-កម្រៃអាជ្ញាបណ្ណអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| |

| |
|---|
| **ជំពូកទី៤**<br>**ភាពកិច្ចរបស់អភិបាលបណ្ដោះអាសន្នក្នុងសំណុំរឿងក្ស័យធន**<br>**(ប្រការ១១ដល់ប្រការ១៧)** |
| ប្រការ១១.- កាតព្វកិច្ចផ្តល់របាយការណ៍ និងឯកសារពាក់ព័ន្ធអភិបាលបណ្ដោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| ប្រការ១២.- កាតព្វកិច្ចជូនដំណឹងអំពីការផ្លាស់ប្តូរទីកន្លែងបំពេញការងារ និងព័ត៌មានទំនាក់ទំនងអភិបាលបណ្ដោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| ប្រការ១៣.-កាតព្វកិច្ចផ្តល់កិច្ចសហការក្នុងការចុះត្រួតពិនិត្យរបស់មន្ត្រីជំនាញនៃក្រសួងយុត្តិធម៌ |
| ប្រការ១៤ .- ការតម្រូវឱ្យមានកិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈ និងព័ត៌មានពាក់ព័ន្ធនានា |
| ប្រការ១៥.-កាតព្វកិច្ចគោរពក្រមសីលធម៌វិជ្ជាជីវៈជាអភិបាលបណ្ដោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| ប្រការ១៦.-កាតព្វកិច្ចរក្សាទុកកំណត់ត្រា ឯកសារ និងទិន្នន័យផ្សេងៗ អភិបាល បណ្ដោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| ប្រការ១៧ - កាតព្វកិច្ចចូលរួមវគ្គបណ្តុះបណ្តាល |
| **ជំពូកទី៥**<br>**ការដកហូតអាជ្ញាបណ្ណ (ប្រការ១៨)** |
| ប្រការ១៨ - ការដកហូតអាជ្ញាបណ្ណជាអភិបាលបណ្ដោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| **ជំពូកទី៦**<br>**ទោសប្បញ្ញត្តិ**<br>**(ប្រការ១៩)** |
| ប្រការ១៩.-ទណ្ឌកម្មរដ្ឋបាល |
| **ជំពូកទី៧**<br>**អន្តរប្បញ្ញត្តិ**<br>**(ប្រការ២២ ដល់ប្រការ២៣)** |
| ប្រការ២២.- ការបន្តសុពលភាពនៃអាជ្ញាបណ្ណជាអភិបាលបណ្ដោះអាសន្នក្នុងសំណុំរឿងក្ស័យធន ទទួលបានមុនកាលបរិច្ឆេទអនុវត្តនៃប្រកាសនេះ |

| |
|---|
| ប្រការ២៣-ការព្យួរមិនអនុវត្តនូវការតម្រូវឱ្យមានកិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈរបស់អភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន |
| **ជំពូកទី៨ អវសានប្បញ្ញត្តិ (ប្រការ២៤ដល់ប្រការ២៥)** |
| ប្រការ២៤.-បដិវាទកម្ម |
| ប្រការ២៥.-ការអនុវត្ត |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៦៧ កយ.ប្រក/២៦

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្ន ក្នុងសំណុំរឿងក្ស័យធន

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការ តែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣១ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីក្ស័យធន
- បានឃើញអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងយុត្តិធម៌

# សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

### ប្រការ១ .. គោលបំណង និងគោលដៅ

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការផ្តល់អាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្ន ក្នុងសំណុំរឿងក្ស័យធន ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការដោះស្រាយសំណុំរឿងក្ស័យធន



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

តាមរយៈការពង្រឹងការគ្រប់គ្រងអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

### ប្រការ២ .- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ដែលទទួលបានអាជ្ញាបណ្ណពីក្រសួងយុត្តិធម៌ដោយអនុលោមតាមច្បាប់ស្តីពីក្ស័យធននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## ស្ថាប័នមានសមត្ថកិច្ច

### ប្រការ៣ .- ការផ្តល់អាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន

បុគ្គលដែលមានបំណងក្លាយជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ត្រូវស្នើសុំអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន និងត្រូវដាក់ពាក្យស្នើសុំមកក្រសួងយុត្តិធម៌ ស្របតាមលក្ខខណ្ឌ បែបបទ និងនីតិវិធីដែលកំណត់ដោយប្រកាសនេះ។

ការផ្តល់អាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

### ប្រការ៤ .- បញ្ជីថ្នាក់ជាតិនៃអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន

អភិបាលបណ្តោះអាសន្នដែលអាចត្រូវបានតែងតាំងដោយតុលាការក្នុងសំណុំរឿងក្ស័យធនត្រូវជ្រើសរើសចេញពីបញ្ជីថ្នាក់ជាតិនៃអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ដែលត្រូវបានរៀបចំ និងធ្វើបច្ចុប្បន្នភាពជាប្រចាំដោយក្រសួងយុត្តិធម៌។

## ជំពូកទី៣
## លក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការផ្តល់ អាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន

### ប្រការ៥ .- លក្ខខណ្ឌស្នើសុំអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន

បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

១- ជារូបវន្តបុគ្គលដែលមានសញ្ជាតិខ្មែរ

២- មានសញ្ញាបត្រចាប់ពីកម្រិតឧត្តមសិក្សា ឬសញ្ញាបត្រដែលមានតម្លៃប្រហាក់ប្រហែល លើជំនាញ នីតិសាស្ត្រ ពាណិជ្ជកម្ម ហិរញ្ញវត្ថុ គណនេយ្យ សវនកម្ម និងគ្រប់គ្រងធុរកិច្ច

៣- មានបទពិសោធយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ លើការងារជំនាញដែលបានរៀបរាប់ក្នុងចំណុចទី២ ខាងលើ

៤- មានទីកន្លែងបំពេញការងារជាអភិបាលបណ្តោះអាសន្ននៅក្នុងព្រះរាជាណាចក្រកម្ពុជា

៥- មិនស្ថិតនៅក្នុងករណីណាមួយដូចខាងក្រោម៖

ក- ធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយចេតនា

ខ- ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា

គ- ធ្លាប់ធ្វើជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតភាគច្រើនដាច់ខាត ឬធ្លាប់ជាអភិបាលនៃក្រុមហ៊ុនណាមួយដែលត្រូវបានប្រកាសក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំ

ឃ- មានស្ថានភាពដែលអាចជឿជាក់ថាបុគ្គលដាក់ពាក្យស្នើសុំ មិនអាចធ្វើសកម្មភាពក្រោមលក្ខខណ្ឌអាជ្ញាបណ្ណប្រកបដោយប្រសិទ្ធភាព និងភាពស្មោះត្រង់

ង- មានស្ថានភាពដែលអាចជឿជាក់ថាបុគ្គលដាក់ពាក្យស្នើសុំ មិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍របស់ម្ចាស់បំណុល និងកូនបំណុល ដោយសារបញ្ហាពាក់ព័ន្ធនឹងកេរ្តិ៍ឈ្មោះ សុចរិតភាព និងភាពដែលអាចទុកចិត្តបាន។

## ប្រការ៦ _ បែបបទ និងនីតិវិធីសម្រាប់ស្នើសុំអាជ្ញាបណ្ណជាអភិបាលបណ្ដោះអាសន្នក្នុងសំណុំរឿងក្ស័យធន

បុគ្គលដែលមានបំណងដាក់ពាក្យស្នើសុំអាជ្ញាបណ្ណជាអភិបាលបណ្ដោះអាសន្នក្នុងសំណុំរឿងក្ស័យធន ត្រូវបំពេញពាក្យស្នើសុំតាមទម្រង់ដែលកំណត់ដោយក្រសួងយុត្តិធម៌ និងដោយភ្ជាប់មកជាមួយនូវឯកសារចាំបាច់ដូចខាងក្រោម៖

១- បង្កាន់ដៃបង់ប្រាក់ពិនិត្យសិក្សាលើពាក្យស្នើសុំអាជ្ញាបណ្ណ

២- អត្តសញ្ញាណប័ណ្ណថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ

៣- សញ្ញាបត្រថតចម្លងដោយមានបញ្ជាក់ត្រឹមត្រូវ

៤- លិខិតបញ្ជាក់បទពិសោធការងារ

៥- ប្រវត្តិរូបសង្ខេបរបស់អ្នកស្នើសុំអាជ្ញាបណ្ណ ដោយមានភ្ជាប់រូបថត ៤ x ៦ ចំនួន ៣ សន្លឹក

៦- ព្រឹត្តិបត្រថ្កោលទោសដែលចេញដោយក្រសួងយុត្តិធម៌។

ក្រោយពីបានពិនិត្យ សិក្សា និងវាយតម្លៃលើសំណុំឯកសារស្នើសុំខាងលើ ក្រសួងយុត្តិធម៌មានសិទ្ធិសម្រេចផ្តល់អាជ្ញាបណ្ណ ឬមិនផ្តល់អាជ្ញាបណ្ណ ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបានទទួលសំណុំឯកសារគ្រប់គ្រាន់។ ក្នុងករណីពាក្យស្នើសុំអាជ្ញាបណ្ណត្រូវបានបដិសេធ ក្រសួងយុត្តិធម៌ត្រូវធ្វើការជូនដំណឹងទៅបុគ្គលដាក់ពាក្យស្នើសុំ ដោយមានបញ្ជាក់អំពីមូលហេតុនៃការបដិសេធ។

កម្រៃពិនិត្យសិក្សាលើពាក្យស្នើសុំអាជ្ញាបណ្ណ មិនត្រូវប្រគល់ត្រឡប់ជូនបុគ្គលដាក់ពាក្យស្នើសុំនោះទេ បើទោះបីពាក្យស្នើសុំត្រូវបានបដិសេធក៏ដោយ។

## ប្រការ៧ _ ការតម្រូវបន្ថែមសម្រាប់ការផ្តល់អាជ្ញាបណ្ណជាអភិបាលបណ្ដោះអាសន្នក្នុងសំណុំរឿងក្ស័យធន

ក្រសួងយុត្តិធម៌អាចតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណជាអភិបាលបណ្ដោះអាសន្នក្នុងសំណុំរឿងក្ស័យធន ផ្តល់ឯកសារបន្ថែម ឬបំភ្លឺនូវចំណុច ឬព័ត៌មានផ្សេងទៀតតាមការចាំបាច់ដើម្បីធានាថាបុគ្គលដាក់ពាក្យស្នើសុំ បានបំពេញគ្រប់លក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះ។

## ប្រការ៨ _ រយៈពេលសុពលភាពនៃអាជ្ញាបណ្ណជាអភិបាលបណ្ដោះអាសន្នក្នុងសំណុំរឿងក្ស័យធន

អាជ្ញាបណ្ណជាអភិបាលបណ្ដោះអាសន្នក្នុងសំណុំរឿងក្ស័យធនមានសុពលភាពរយៈពេល ២ (ពីរ) ឆ្នាំ ហើយអាចបន្តសុពលភាពជាថ្មីសម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ ម្តងៗ។

**ប្រការ៩ .. ការស្នើសុំបន្តអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន**

អភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធនត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន មកក្រសួងយុត្តិធម៌ឱ្យបានយ៉ាងតិច ៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ។

ក្រសួងយុត្តិធម៌មានសិទ្ធិសម្រេចបន្តអាជ្ញាបណ្ណ ឬមិនបន្តអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបានទទួលពាក្យស្នើសុំបន្តអាជ្ញាបណ្ណ។ ក្នុងករណីពាក្យស្នើសុំបន្តអាជ្ញាបណ្ណត្រូវបានបដិសេធ ក្រសួងយុត្តិធម៌ត្រូវធ្វើការជូនដំណឹងទៅបុគ្គលដាក់ពាក្យស្នើសុំ ដោយមានបញ្ជាក់អំពីមូលហេតុនៃការបដិសេធ។

**ប្រការ១០ .. កម្រៃអាជ្ញាបណ្ណអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន និងកម្រៃផ្សេងៗ**

កម្រៃពិនិត្យសិក្សាលើពាក្យស្នើសុំអាជ្ញាបណ្ណ កម្រៃអាជ្ញាបណ្ណ និងកម្រៃបន្តអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ត្រូវកំណត់ដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ជំពូកទី៤
## ភារកិច្ចរបស់អភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន

**ប្រការ១១ .. ភារកិច្ចផ្តល់របាយការណ៍ និងឯកសារពាក់ព័ន្ធ**

អភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ត្រូវផ្តល់ជូនក្រសួងយុត្តិធម៌យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែតុលា នៅរៀងរាល់ឆ្នាំនីមួយៗ នូវរបាយការណ៍ និងឯកសារពាក់ព័ន្ធដូចខាងក្រោម៖

១- ព័ត៌មានពាក់ព័ន្ធនឹងសំណុំរឿងក្ស័យធននៅតុលាការដែលសាមីខ្លួនទទួលបន្ទុក ដោយត្រូវមានខ្លឹមសារចាំបាច់ជាអាទិ៍៖

- ចំនួនសំណុំរឿង ប្រភេទបុគ្គលដែលប្តឹងសុំបើកសំណុំរឿង និងកម្មវត្ថុសំណុំរឿង
- ចំនួនសំណុំរឿងក្ស័យធនដែលមានការស្តារនីតិសម្បទា និង/ឬមានការជម្រះបញ្ជី ចំនួនម្ចាស់បំណុល និងកូនបំណុល
- អត្ថិភាព ឬនត្ថិភាពនៃផែនការសម្របសម្រួលក្នុងសំណុំរឿងក្ស័យធននីមួយៗ
- បញ្ជីរាយនាមបុគ្គលជំនួយរបស់អភិបាលបណ្តោះអាសន្ននៅក្នុងសំណុំរឿងក្ស័យធននីមួយៗ ដោយត្រូវមានបញ្ជាក់អំពីមុខងារ និងតួនាទី។

២- បញ្ហាប្រឈមក្នុងការបំពេញមុខងារជាអភិបាលបណ្តោះអាសន្ន។

៣- សេចក្តីសម្រេចបញ្ចប់សំណុំរឿងក្ស័យធនរបស់តុលាការ ដែលអភិបាលបណ្តោះអាសន្នទទួលបន្ទុក។

៤- របាយការណ៍ ឯកសារ ឬព័ត៌មានផ្សេងទៀតដែលកំណត់ដោយក្រសួងយុត្តិធម៌។

**ប្រការ១២ .. ភារកិច្ចជូនដំណឹងអំពីការផ្លាស់ប្តូរទីកន្លែងបំពេញការងារ និងព័ត៌មានទំនាក់ទំនង**

អភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងយុត្តិធម៌អំពីការផ្លាស់ប្តូរទីកន្លែងបំពេញការងារ និងព័ត៌មានសម្រាប់ធ្វើការទំនាក់ទំនង ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីការផ្លាស់ប្តូរនោះ។

**ប្រការ១៣ .. កាតព្វកិច្ចផ្តល់កិច្ចសហការក្នុងការចុះត្រួតពិនិត្យរបស់មន្ត្រីជំនាញនៃក្រសួងយុត្តិធម៌**

ក្នុងករណីចាំបាច់ មន្ត្រីជំនាញនៃក្រសួងយុត្តិធម៌អាចចុះទៅទីកន្លែងបំពេញការងាររបស់អភិបាលបណ្តោះអាសន្ន ដើម្បីត្រួតពិនិត្យការអនុវត្តនូវលក្ខខណ្ឌអាជ្ញាបណ្ណ និងកាតព្វកិច្ចនានារបស់អភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធនដែលកំណត់ក្នុងប្រកាសនេះ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។ ក្នុងករណីនេះ អភិបាលបណ្តោះអាសន្នត្រូវចូលរួមសហការ ព្រមទាំងផ្តល់នូវឯកសារ និងព័ត៌មានពាក់ព័ន្ធនានាជូនទៅមន្ត្រីជំនាញនៃក្រសួងយុត្តិធម៌ដែលចុះទៅបំពេញការងារនោះ។

**ប្រការ១៤ .. ការតម្រូវឱ្យមានកិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈ**

មុនពេលចាប់ផ្តើមប្រតិបត្តិការសកម្មភាពរបស់ខ្លួន អភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធនត្រូវមានកិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈជាមួយក្រុមហ៊ុនមានការទទួលស្គាល់ដោយក្រសួងយុត្តិធម៌ សម្រាប់ធានាការទទួលខុសត្រូវក្នុងការបំពេញមុខងាររបស់ខ្លួន។

**ប្រការ១៥ .. កាតព្វកិច្ចគោរពក្រមសីលធម៌វិជ្ជាជីវៈជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន**

អភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ត្រូវគោរពឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈជាអភិបាលបណ្តោះអាសន្ន ដែលកំណត់ក្នុងប្រកាសដោយឡែករបស់ក្រសួងយុត្តិធម៌។

**ប្រការ១៦ .. កាតព្វកិច្ចរក្សាទុកកំណត់ត្រា ឯកសារ និងទិន្នន័យផ្សេងៗ**

អភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ត្រូវរក្សាទុកកំណត់ត្រានៃសំណុំរឿងក្ស័យធនដែលខ្លួនទទួលបន្ទុក និងរាល់ឯកសារប្រតិបត្តិការជាប្រាក់ទាំងអស់ ក្នុងរយៈពេលយ៉ាងតិច ៦ (ប្រាំមួយ) ឆ្នាំ គិតចាប់ពីថ្ងៃបិទបញ្ចប់សំណុំរឿង។ កំណត់ត្រា ឯកសារ និងទិន្នន័យទាំងអស់ត្រូវរក្សាទុកនៅទីកន្លែងដែលមានសុវត្ថិភាព និងដែលអាចអនុញ្ញាតឱ្យមន្ត្រីជំនាញនៃក្រសួងយុត្តិធម៌ធ្វើអធិការកិច្ចត្រួតពិនិត្យបាន។

**ប្រការ១៧ .. កាតព្វកិច្ចចូលរួមវគ្គបណ្តុះបណ្តាល**

អភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ត្រូវចូលរួមវគ្គបណ្តុះបណ្តាលនានា ដែលរៀបចំដោយក្រសួងយុត្តិធម៌ ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានការអនុញ្ញាតពីក្រសួងយុត្តិធម៌។

## ជំពូកទី៥
## ការដកហូតអាជ្ញាបណ្ណ

**ប្រការ១៨ .. ការដកហូតអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន**

ក្រសួងយុត្តិធម៌ អាចសម្រេចដកហូតអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធនក្នុងករណីណាមួយដូចខាងក្រោម៖

១- ការទទួលបានអាជ្ញាបណ្ណ ឬការបន្តអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធនដោយសេចក្តីថ្លែងមិនពិត ឬដោយមធ្យោបាយទុច្ចរិតណាមួយ។

២- ការមិនបានបំពេញនូវកាតព្វកិច្ចដូចមានចែងក្នុងប្រកាសនេះ ឬក្នុងលក្ខខណ្ឌអាជ្ញាបណ្ណ ឬមិនបានកែតម្រូវកំហុសណាមួយ តាមការណែនាំរបស់ក្រសួងយុត្តិធម៌។

៣- ការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដោយចេតនា។

៤- ការប្រព្រឹត្តកំហុសវិជ្ជាជីវៈធ្ងន់ធ្ងរក្នុងអំឡុងពេលបំពេញមុខងារជាអភិបាលបណ្តោះអាសន្ន។

៥- ការបាត់បង់សមត្ថភាពក្នុងការបំពេញមុខងារ។

៦- ការស្នើសុំរបស់សាមីខ្លួន។

ការដកហូតអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

### ប្រការ១៩ _ ទណ្ឌកម្មរដ្ឋបាល

អភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ដែលមិនអនុវត្តនូវកាតព្វកិច្ចដូចមានចែងក្នុងប្រកាសនេះ និងលក្ខខណ្ឌអាជ្ញាបណ្ណ ត្រូវទទួលរងទណ្ឌកម្មរដ្ឋបាលណាមួយ ដូចខាងក្រោម៖

១- ការស្តីបន្ទោសដោយផ្ទាល់មាត់។

២- ការស្តីបន្ទោសជាលាយលក្ខណ៍អក្សរដោយមានចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន។

៣- ការព្យួរអាជ្ញាបណ្ណ។

៤- ការដកហូតអាជ្ញាបណ្ណ។

ការសម្រេចអំពីទណ្ឌកម្មរដ្ឋបាល ដូចមានចែងក្នុងចំណុចទី១ និងទី២ នៃកថាខណ្ឌខាងលើ ត្រូវធ្វើឡើងតាមការសម្រេចពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ការសម្រេចអំពីទណ្ឌកម្មរដ្ឋបាល ដូចមានចែងក្នុងចំណុចទី៣ និងទី៤ នៃកថាខណ្ឌខាងលើ អាចត្រូវបានធ្វើឡើង លុះណាតែអភិបាលបណ្តោះអាសន្នដែលរងការចោទប្រកាន់ ត្រូវបានកោះហៅមកធ្វើការឆ្លើយបំភ្លឺការពារខ្លួន។ ការសម្រេចអំពីទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងកថាខណ្ឌនេះ ត្រូវធ្វើឡើងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

រាល់ការសម្រេចដាក់ទណ្ឌកម្មព្យួរ ឬដកហូតអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ត្រូវចុះនិទ្ទេសនៅក្នុងបញ្ជីថ្នាក់ជាតិនៃអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន និងត្រូវធ្វើជូនទៅសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។

### ប្រការ២០ _ ការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ និងការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីបន្ថែមផ្សេងទៀត

ការទទួលរងនូវទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងប្រការ ១៩ នៃប្រកាសនេះ ពុំរារាំងដល់ការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ និងការទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណីបន្ថែមទៀតនោះទេ។

### ប្រការ២១ _ ការអនុវត្តមុខងារជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធនដោយខុសច្បាប់

បុគ្គលទាំងឡាយណាដែលអះអាងថាខ្លួនជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ដោយគ្មានអាជ្ញាបណ្ណពីក្រសួងយុត្តិធម៌ ឬអភិបាលបណ្តោះអាសន្នដែលអនុវត្តមុខងាររបស់ខ្លួន ដោយប្រើប្រាស់នូវអាជ្ញាបណ្ណដែលផុតសុពលភាព ត្រូវផ្តន្ទាទោសតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៧
## អន្តរប្បញ្ញត្តិ

**ប្រការ២២ .- ការបន្តសុពលភាពនៃអាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ដែលទទួលបានមុនកាលបរិច្ឆេទអនុវត្តនៃប្រកាសនេះ**

អាជ្ញាបណ្ណជាអភិបាលបណ្តោះអាសន្នដែលទទួលបាននៅមុនកាលបរិច្ឆេទអនុវត្តនៃប្រកាសនេះ ត្រូវបន្តមានសុពលភាព រហូតដល់កាលបរិច្ឆេទផុតសុពលភាពនៃអាជ្ញាបណ្ណនោះ។

ក្រោយផុតសុពលភាពអាជ្ញាបណ្ណដូចមានកំណត់ក្នុងកថាខណ្ឌទី១ ខាងលើ ការស្នើសុំអាជ្ញាបណ្ណ ជាអភិបាលបណ្តោះអាសន្នក្នុងសំណុំរឿងក្ស័យធន ត្រូវអនុវត្តស្របតាមបញ្ញត្តិនៃប្រកាសនេះ។

**ប្រការ២៣ .- ការព្យួរមិនអនុវត្តនូវការតម្រូវឱ្យមានកិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈរបស់អភិបាលបណ្តោះ-អាសន្នក្នុងសំណុំរឿងក្ស័យធន**

ចំពោះកាតព្វកិច្ចតម្រូវឱ្យមាននូវកិច្ចសន្យាធានារ៉ាប់រងវិជ្ជាជីវៈជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលទទួលស្គាល់ដោយក្រសួងយុត្តិធម៌ ដូចមានចែងក្នុងប្រការ១៤ នៃប្រកាសនេះ ត្រូវបានព្យួរមិនអនុវត្ត រហូតដល់មានការកំណត់ផ្សេងក្នុងប្រកាសដោយឡែករបស់ក្រសួងយុត្តិធម៌។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**ប្រការ២៤ .- បដិវាទកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៥ .- ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៣ កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មីនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កើត រិទ្ធ

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ២៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ